ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៨០/០៩-សិប្បកម្មត្បាញភូមិព្រែកត្រែង**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៩**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **កៅ ថាច**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **វ៉ែន ពៅ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **អាំង អេងថុង**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : **សិប្បកម្មត្បាញភូមិព្រែកត្រែង**

អាសយដ្ឋាន : ភូមិព្រែកត្រែង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល

ទូរស័ព្ទ : ០១២ ៦២៦ ៨៦៨ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោក ហ៊ំ ភា | មេធាវីតំណាងដោយអាណត្តិ |
| ២- លោក អោក ហួរ | តំណាងសិប្បកម្ម |
| ៣- លោក រឹម វីរៈ | ជំនួយការមេធាវី |

២- ភាគីកម្មករនិយោជិត

ឈ្មោះ : **សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា(ស៊ីខៅឌូ)**

អាសយដ្ឋាន : ផ្ទះលេខ ២, ៣ G ផ្លូវលេខ ២៦ BT ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ភ្នំពេញ

លេខទូរស័ព្ទ : ០១២ ២៨២ ៦៥៣ លេខទូរសារ : គ្មាន



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិត:

| | |
|---|---|
| ១- លោក អ៊ុំ វិសាល | មន្ត្រីសម្ព័ន្ធសហជីព ស៊ីខៅឌូ |
| ២- លោក ធួក ចំរើន | តំណាងកម្មករ |
| ៣- លោក កែវ វិបុល | តំណាងកម្មករ |
| ៤- កញ្ញា សែន សុខពេញ | តំណាងកម្មករ |
| ៥- កញ្ញា ធី សុខុម | តំណាងកម្មករ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- គិតតម្លៃឡូត៍ឱ្យបានសមរម្យឱ្យដល់កម្មករ ហើយត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ។

២- នៅពេលបើកលុយ ក្រុមហ៊ុនត្រូវមានវិក្កយប័ត្របើកលុយឱ្យបានច្បាស់លាស់ជូនដល់កម្មករ ។

៣- សូមឱ្យក្រុមហ៊ុនគិតថ្លៃបាយពេលធ្វើការថែមម៉ោង និងថ្ងៃបុណ្យជូនកម្មករ ។

៤- សូមឱ្យក្រុមហ៊ុនបើកលុយយ៉ាងយូរបំផុតត្រឹមថ្ងៃទី០៩ ជារៀងរាល់ខែ ។

៥- ចេញតម្លៃឡូត៍មុនផ្តល់ការងារឱ្យដល់កម្មករធ្វើ ។

៦- បើកប្រាក់លំហែមាតុភាពដល់កម្មករចាប់ពីមួយឆ្នាំឡើងទៅ ។

៧- អ្នកពោះធំ និងកូនខ្ចីចេញមុនម៉ោង ១៥ នាទី ។

៨- អ្នកឆ្លងទន្លេចត្រូវផ្តល់រយៈពេលមួយម៉ោងសំរាប់បំបៅដោះកូន បើមិនឱ្យចេញ ក្រុមហ៊ុនត្រូវផ្តល់លុយចំនួន ២០ ដុល្លារក្នុងមួយខែ ។

៩- ក្រុមហ៊ុនត្រូវចេញកាតឱ្យដល់កម្មករដោយមានបញ្ជាក់ឈ្មោះក្រុមហ៊ុន ឈ្មោះកម្មករ អត្តលេខ ផ្នែក និងថ្ងៃ ខែ ឆ្នាំ ឱ្យបានច្បាស់លាស់ជូនដល់កម្មករនិយោជិតទាំងអស់ ។

១០- សូមឱ្យក្រុមហ៊ុនរៀបចំការបោះឆ្នោតជ្រើសរើសតំណាងកម្មករយ៉ាងយូរបំផុតខែកក្កដា ។

១១- សូមធ្វើកិច្ចសន្យាការងារ ០៦ ខែម្តង សម្រាប់កម្មករដែលមានកិច្ចសន្យាកំណត់ ។

១២- សូមកុំឱ្យមានការបញ្ឈប់ដោយមូលហេតុចប់កិច្ចសន្យាការងារក្រៅអំពីកំហុសជាអតិបរមា ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុង និងច្បាប់ស្តីពីការងារ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជា

ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ ( អាណត្តិទី៥ ) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ ( ក ) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ២២២/០៩ កប/កណ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩ ។

**សវនាការ និង សន្ទេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល**

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ ( វេលាម៉ោង ១៤:០០ នាទី រសៀល ) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានទទួលបណ្តឹងរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា នៃក្រុមហ៊ុនសិប្បកម្មត្បាញភូមិព្រែកព្រៃង ទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ ដោយបានទទួលលទ្ធផលសះជាលើការទាមទារចំនួន១០ចំណុច និងមិនសះជាចំនួន១២ចំណុច ក្នុងចំណោមការទាមទារទាំងអស់ចំនួន ២២ ចំណុច ។ ចំណុចមិនសះជាចំនួន ១២ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៩ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន១២ចំណុចនេះ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ( វេលាម៉ោង ១៤:០០ នាទី ) ។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

នៅថ្ងៃសវនាការ ភាគីទាំងពីរបានបញ្ជាក់ពីការព្រមព្រៀងរបស់ភាគីមុនថ្ងៃសវនាការថា ភាគីបានព្រមព្រៀងគ្នាលើការទាមទារ១១ចំណុចបន្ថែមទៀត ដូច្នេះ នៅសល់តែ០១ចំណុចប៉ុណ្ណោះ សម្រាប់ដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០១ ចំណុច គឺចំណុចទី៥ នៅក្នុងរបាយការណ៍មិនសះជា ប៉ុន្តែមិនបានទទួលលទ្ធផលសះជាទេ ។ ហេតុនេះហើយ នៅក្នុង

សំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើចំណុចទាមទារនេះ ដោយផ្អែកលើភស្តុតាង និង ហេតុផលដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់អាណត្តិទាយកនៃសិប្បកម្មត្បាញភូមិព្រែកព្រែង ជូន លោកមេធាវី ហំ ភា ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៩ ។

២- កំណត់ហេតុចរចាដោះស្រាយវិវាទនៃសិប្បកម្មត្បាញភូមិព្រែកព្រែង ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០០៩ ។

៣- កំណត់ហេតុចរចាដោះស្រាយវិវាទនៃសិប្បកម្មត្បាញភូមិព្រែកព្រែង ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០០៩ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- កំណត់ហេតុចរចាដោះស្រាយវិវាទនៃសិប្បកម្មត្បាញភូមិព្រែកព្រែង ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០០៩ ។

២- កំណត់ហេតុចរចាដោះស្រាយវិវាទនៃសិប្បកម្មត្បាញភូមិព្រែកព្រែង ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០០៩ ។

៣- សារណាលើសំណុំរឿងលេខ ០៨/០៩ នៃរោងចក្រ ព្រែកព្រែង លេខ ៥៨/០៩ ស.ប.ក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ។

៤- ស្នាមមេដៃរបស់កម្មករនិយោជិតនៃរោងចក្រ ព្រែកព្រែង ផ្ទេរសិទ្ធិជូនប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ដើម្បីដោះស្រាយវិវាទការងាររបស់យើងខ្ញុំជាមួយនឹងក្រុមហ៊ុន ព្រែកព្រែង ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅសិប្បកម្មត្បាញភូមិព្រែកព្រែងលេខ ២២២/០៩ កប/ កណ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៩។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់សិប្បកម្មត្បាញភូមិព្រែកព្រែង ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៣៨៤ កប/អក/វក/លកអ. ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៣៨៥ កប/អក/វក/លកអ. ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន សិប្បកម្មត្បាញភូមិព្រែកត្រែង មានទីតាំងស្ថិតនៅភូមិព្រែកត្រែង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល មានជួលកម្មករនិយោជិតសរុបចំនួន ១២០០ នាក់ ដែលជាភាគីចុងចម្លើយ ហើយក្រុមហ៊ុននេះមិនទាន់បានចុះបញ្ជីក្រុមហ៊ុនរបស់ខ្លួននៅឡើយទេ។
- ភាគីកម្មករនិយោជិត ដែលភាគីនៃដើមបណ្តឹងក្នុងរឿងនេះ តំណាងដោយសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (ស៊ីខៅឌូ) ហើយសហជីពនេះមិនទាន់បានចុះបញ្ជិកានៅក្រសួងនៅឡើយដែរ។
- ក្រោយពីពិនិត្យឯកសារ ដែលដាក់មកដោយភាគីទាំងពីរ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីខាងក្រុមហ៊ុនតំណាងដោយលោក អោក ហួរ។ រីឯភាគីកម្មករនិយោជិតវិញមានកម្មករនិយោជិត ដែលផ្តិតមេដៃទាមទារចំនួន៨៨៤នាក់ ដោយផ្ទេរសិទ្ធិឱ្យសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (ស៊ីខៅឌូ) ជួយដោះស្រាយការទាមទាររបស់ខ្លួន។

**ចំណុចវិវាទទី៥: កម្មករនិយោជិតទាមទារចេញតម្លៃឡូតិ៍មុនផ្តល់ការងារដល់កម្មករនិយោជិត**

- ភាគីនិយោជក និងភាគីកម្មករនិយោជិត បានទទួលស្គាល់ថា កម្មករនិយោជិតដេរស៊ីតាមឡូតិ៍មានចំនួនសរុបប្រហែលពី ៨០០ នាក់ ទៅ ៩០០ នាក់ ហើយកម្មករដេរស៊ីតាមឡូតិ៍ទាំងអស់នោះធ្វើការនៅផ្នែកផែក ប៉ះ អ៊ុត វាស់ ផុង វាយឡេវ និងផ្នែកដេរផ្កាកក។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា កន្លងមកនិយោជកមិនដែលប្រាប់ឱ្យបានដឹងជាមុនអំពីតម្លៃឡូតិ៍ទេ ចាំដល់ពេលដាច់ខែ នៅពេលបើកប្រាក់ឈ្នួលប្រចាំខែឱ្យដល់កម្មករនិយោជិតតែម្តង ដោយមិនបានដឹងជាមុនថា តម្លៃដេរស៊ីឡូតិ៍នោះបានថ្លៃប៉ុន្មានទេ។

- ភាគីនិយោជកបញ្ជាក់ថា ខ្លួនមិនបានដឹងអំពីតម្លៃឡូត៍នោះដែរ ព្រោះការកំណត់តម្លៃនេះមាននៅតែការិយាល័យគណនេយ្យប៉ុណ្ណោះ តែនៅរៀងរាល់ព្រឹកនិយោជកបានបិទនូវតារាងបញ្ជីចំនួនឡូត៍ ដែលកម្មករនិយោជិតដេរបាន ដោយមិនមានប្រាប់អំពីតម្លៃឡូត៍នីមួយៗទេ ភាគីកម្មករនិយោជិតយល់ស្រប ចំពោះការលើកឡើង របស់ភាគីនិយោជកខាងលើ ។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា ខ្លួននៅតែសុំនិយោជក ឱ្យកម្មករដេរសាកល្បងរយៈពេល០៣ថ្ងៃ ហើយនៅថ្ងៃទី៤ និយោជកត្រូវចេញតម្លៃឡូត៍ឱ្យកម្មករដឹង ព្រោះថានៅក្រុមហ៊ុនផ្សេងៗមួយចំនួន ដែលស្ថិតនៅជិតរោងចក្រនេះ ក៏គេបានអនុវត្តបែបនេះដែរ គឺ ចេញតម្លៃឡូត៍រយៈពេលពី០៣ថ្ងៃ ទៅ០៤ថ្ងៃប៉ុណ្ណោះ ឱ្យកម្មករដឹងមុន ដែលមានដូចជា ក្រុមហ៊ុន ហ្វារចូន និងក្រុមហ៊ុន វីវើរីច ជាដើម ។
- ភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនសុំរយៈពេល០៧ថ្ងៃ ទើបអាចចេញតម្លៃឡូត៍ឱ្យដល់កម្មករដឹងបាន ដោយមូលហេតុថា ក្រុមហ៊ុនត្រូវការគិតពីតម្លៃទឹក ភ្លើង និងសន្តិសុខ ជាពិសេសគិតពីបញ្ហាខាត ឬចំណេញសិន ។
- កម្មករនិយោជិតនៅតែទាមទារក្នុងរយៈពេល០៤ថ្ងៃ ឱ្យនិយោជកចេញតម្លៃឡូត៍ ដោយបញ្ជាក់នូវហេតុផលថា:

  ១. ក្រុមហ៊ុនដទៃជិតៗគ្នា ប្រហាក់ប្រហែលគ្នា គេអាចធ្វើបាន ។

  ២. ផ្តល់លទ្ធភាពឱ្យក្រុមហ៊ុនរយៈពេល០៣ថ្ងៃ ហើយឱ្យសាកល្បង និងសុំចេញតម្លៃឡូត៍ នៅថ្ងៃទី០៤ ។

  ៣. ដោយក្រុមហ៊ុននេះ ទទួលផលិតផលពាក់កណ្តាលសម្រេច ដើម្បីធ្វើបន្តពីក្រុមហ៊ុនផ្សេង ហេតុនេះ មានលទ្ធភាពច្រើនក្នុងការវាយតម្លៃជាមុនបានហើយ ដោយការទទួលនេះមិនជាច្រើនពេកទេ ។

  ៤. កម្មករទទួលបរិមាណផលិតផលពីក្រុមហ៊ុនត្រូវតែឱ្យដឹងជាមុន អំពីតម្លៃឡូត៍ដែលខ្លួនបានធ្វើជាក់ស្តែង ហើយក្រុមហ៊ុនត្រូវមានកាតព្វកិច្ចឱ្យកម្មករនិយោជិតបានដឹងជាមុន ។

- ភាគីក្រុមហ៊ុនឆ្លើយតបទៅនឹងការលើកឡើងពីមូលហេតុទាំងបួនរបស់ភាគីកម្មករវិញថា ការសុំឱ្យដូចក្រុមហ៊ុនគេនោះ គឺអាស្រ័យលើលទ្ធភាពរបស់ក្រុមហ៊ុនផ្សេងៗគ្នា មិនដូចគ្នាទេ ។ ការសុំនេះ មិនអាចទៅរួចទេ ចំពោះការលើកឡើងថា ការទទួលផលិតផលមិនច្រើននោះ គឺលទ្ធភាព របស់ក្រុមហ៊ុនមិនអាចធ្វើបាន ជាពិសេសករណីនេះមិនមែនជាកាតព្វកិច្ចរបស់ក្រុមហ៊ុន ដែលត្រូវតែឱ្យកម្មករដឹងជាមុននូវតម្លៃឡូត៍នោះទេ ព្រោះមិនមានច្បាប់ណាមួយចែងឡើយ ។
- កម្មករនិយោជិតមិនព្រមទទួលយកការចេញតម្លៃឡូត៍នៅថ្ងៃទី០៧ បន្ទាប់ពីកម្មករនិយោជិតធ្វើការងារលើឡូត៍នោះ ដោយសារតែការងារស៊ីឡូត៍ខ្លះ កម្មករនិយោជិតធ្វើហើយមុន០៧ថ្ងៃ ដូចនេះការ

ចេញតម្លៃឡូត៍នៅថ្ងៃទី០៧ គឺក្រោយពេលកម្មករនិយោជិតធ្វើការលើឡូត៍នោះ ដែលជាហេតុធ្វើឱ្យកម្មករនិយោជិតមិនអាចដឹងតម្លៃឡូត៍មុន។

**ហេតុផលនៃសេចក្តីសម្រេចៈ**

**ចំណុចវិវាទទី៥: កម្មករនិយោជិតទាមទារចេញតម្លៃឡូត៍មុនផ្តល់ការងារដល់កម្មករនិយោជិត**

មុននឹងពិចារណាលើចំណុចទាមទារនៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាលើសមាសភាពនៃភាគីនៅក្នុងវិវាទនេះជាមុនសិន។

យោងតាមអង្គហេតុ ក្រុមហ៊ុន សិប្បកម្មត្បាញភួយព្រែកគ្រែង មានចំនួនកម្មករនិយោជិតសរុបចំនួនប្រហែល ១២០០ នាក់ ដែលជាភាគីចុងចម្លើយ ហើយក្រុមហ៊ុននេះមិនទាន់បានចុះបញ្ជីក្រុមហ៊ុនរបស់ខ្លួននៅឡើយទេ។ មេធាវីក្រុមហ៊ុនបានលើកឡើងថា ក្រុមហ៊ុនកំពុងតែស្ថិតក្នុងដំណើរការចុះបញ្ជិកា។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីក្រុមហ៊ុននៅក្នុងសំណុំរឿងនេះ ត្រូវរៀបចំចុះបញ្ជីក្រុមហ៊ុនឱ្យបានត្រឹមត្រូវទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ចំណែកឯភាគីកម្មករនិយោជិត ដែលភាគីនៃដើមបណ្តឹងក្នុងរឿងនេះ តំណាងដោយសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា(ស៊ីខៅឌូ)។ ចំពោះសហជីពមូលដ្ឋានមិនទាន់បានចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅឡើយដែរ។ ភាគីកម្មករនិយោជិតក៏លើកឡើងដែរថា កំពុងតែស្ថិតក្នុងដំណើរការចុះបញ្ជិកា។ ក្រោយពីពិនិត្យឯកសារ ដែលដាក់មកដោយភាគីទាំងពីរ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីក្រុមហ៊ុនតំណាងដោយលោក អោក ហួរ។ រីឯភាគីកម្មករនិយោជិតវិញមានចំនួន៨៨៤នាក់ ដែលផ្តិតមេដៃទាមទារដោយផ្ទេរសិទ្ធិឱ្យសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (ស៊ីខៅឌូ) ជួយដោះស្រាយការទាមទាររបស់ខ្លួន។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាការទាមទាររបស់កម្មករនិយោជិត និងនិយោជក ដែលតំណាងដោយលោក អោក ហួរ ដូចខាងក្រោម:

និយោជកអាចចេញតម្លៃឡូត៍ឱ្យកម្មករនិយោជិតដឹងបានក្នុងរយៈពេល០៧ថ្ងៃ បន្ទាប់ពីកម្មករនិយោជិតធ្វើការងារលើឡូត៍នោះ ចំណែកឯកម្មករនិយោជិតវិញ ទាមទារឱ្យក្រុមចេញតម្លៃឡូត៍ឱ្យកម្មករនិយោជិតដឹងបានក្នុងរយៈពេល០៤ថ្ងៃ បន្ទាប់ពីកម្មករនិយោជិតធ្វើការងារលើឡូត៍នោះ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចក្នុងការជូនដំណឹងអំពីតម្លៃឡូត៍ដល់កម្មករនិយោជិតដែរ ឬទេ? និងតើនិយោជកត្រូវជូនដំណឹងអំពីតម្លៃឡូត៍ដល់កម្មករនិយោជិតក្នុងរយៈពេលប៉ុន្មានថ្ងៃ?

**១-តើនិយោជកមានកាតព្វកិច្ចក្នុងការជូនដំណឹងអំពីតម្លៃឡូត៍ដល់កម្មករនិយោជិតដែរ ឬ ទេ?**

មាត្រា ១១២ នៃច្បាប់ការងារចែងថា *"និយោជកត្រូវចាត់វិធានការ ដើម្បីឱ្យដំណឹងដល់កម្មករនិយោជិតឱ្យបានច្បាស់ប្រាកដ និងងាយស្រួលយល់ :*

*ក-អំពីល័ក្ខខ័ណ្ឌប្រាក់ឈ្នួលដែលត្រូវអនុវត្តចំពោះកម្មករនិយោជិតទាំងនោះ មុននឹងចូលកាន់តំណែងធ្វើ*

*ការ ឬ នៅគ្រប់ពេលផ្លាស់ប្តូរល័ក្ខខ័ណ្ឌទាំងនេះ ។*

*ខ-អំពីប្រាក់ឈ្នួលទាំងអស់របស់កម្មករនិយោជិតសម្រាប់រយៈពេលបើកប្រាក់ម្តង១ កាលណាប្រាក់ឈ្នួលនោះអាចមានការផ្លាស់ប្តូរ ។"*

តាមខ្លឹមសារ និងអត្ថន័យនៃមាត្រាខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា នៅពេលណាដែលល័ក្ខខ័ណ្ឌការងារ ជាពិសេស គឺកម្រិតប្រាក់ឈ្នួលរបស់កម្មករនិយោជិតប្រែប្រួល និយោជកត្រូវជូនដំណឹងដល់កម្មករនិយោជិតឱ្យច្បាស់លាស់អំពីប្រាក់ឈ្នួល ដែលគេនឹងទទួលបាននាពេលខាងមុខ ។ ផ្អែកលើការបកស្រាយនេះ ការទាមទាររបស់ភាគីកម្មករនិយោជិត ពាក់ព័ន្ធនឹងសិទ្ធិដែលកំណត់ដោយច្បាប់ស្តីពីការងារ ដែលតម្រូវឱ្យនិយោជកមានកាតព្វកិច្ចក្នុងការជូនដំណឹងអំពីល័ក្ខខ័ណ្ឌប្រាក់ឈ្នួលដល់កម្មករនិយោជិត ។

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិត និងភាគីនិយោជកបានឯកភាពថា នៅពេលដែលក្រុមហ៊ុនដាក់ឡូត៍ថ្មីឱ្យកម្មករនិយោជិតធ្វើ បានធ្វើឱ្យមានការប្រែប្រួលទៅលើល័ក្ខខ័ណ្ឌនៃប្រាក់ឈ្នួល ដែលត្រូវអនុវត្តចំពោះកម្មករនិយោជិត ពីព្រោះជូនកាលឡូត៍ថ្មីខ្លះ ដែលមានចំនួនឡូត៍តិចតួច កម្មករអាចធ្វើចប់ក្នុងរយៈពេលខ្លី ។ ហេតុដូច្នេះ និយោជកត្រូវតែជូនដំណឹងដល់កម្មករនិយោជិតអំពីកម្រិតប្រាក់ឈ្នួលថ្មីនោះ ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល*លេខ ១៤/០៣-ជូស៊ីង ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី២ និងលេខ ៧១/០៨ -វីវីរីច ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៣)* ។

**២-តើនិយោជកត្រូវជូនដំណឹងអំពីតម្លៃឡូត៍ដល់កម្មករនិយោជិតក្នុងរយៈពេលប៉ុន្មានថ្ងៃ?**

យោងតាមមាត្រា ១១២ ចំណុច "ក" នៃច្បាប់ស្តីពីការងារ ដូចដែលបានលើកឡើងខាងលើ មិនបានចែងច្បាស់ថា តើនិយោជកត្រូវជូនដំណឹងអំពីប្រាក់ឈ្នួលក្នុងរយៈពេលប៉ុន្មានថ្ងៃនោះឡើយ ។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦២/០៤-អ៊ីស៊ីន ហេតុផលសេចក្តីសម្រេចចំណុចវិវាទទី២ ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើកឡើងថា" *តាមន័យនៃមាត្រា ១១២ ចំណុច-ក នៃច្បាប់ការងារ ដូចដែលបានលើកឡើងខាងលើ គឺមិនមានចែងជាក់លាក់ថា និយោជកត្រូវជូនដំណឹងដល់កម្មករនិយោជិតអំពីប្រាក់ឈ្នួលក្នុងមួយឡូត៍១ ក្នុងរយៈពេលប៉ុន្មានថ្ងៃនោះឡើយ ប៉ុន្តែចំណុច "ក " នៃច្បាប់នេះ មានន័យច្បាស់លាស់ថា និយោជកមានកាតព្វកិច្ចក្នុងការជូនដំណឹងនេះ ។ ចំពោះចំនួនថ្ងៃដែលនិយោជកត្រូវការ ដើម្បីឱ្យអាចជូនដំណឹងទៅកម្មករនិយោជិត ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវពិចារណា ដោយផ្អែកទៅលើសេចក្តីត្រូវការជាក់ស្តែងរបស់ភាគីនិយោជក ។"*

ម្យ៉ាងវិញទៀត នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា រយៈពេលទូទៅសម្រាប់កំណត់តម្លៃឡូត៍ គឺពី ០៣ ថ្ងៃ ទៅ ០៧ ថ្ងៃ ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៥/០៦-ដាប់ប៊ិល យូ អ៊ែនឌី ហេតុផលសេចក្តសម្រេច ចំណុចវិវាទី៧ និងលេខ ០៣/០៧-ឌិយូណាយធីត នីតធីង ហេតុផលសេចក្តីសម្រេច ចំណុចវិវាទី៣)* ។

យោងតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏យល់ស្របដែរថា រយៈពេលទូទៅសម្រាប់កំណត់តម្លៃឡូត៍ គឺពី ០៣ ថ្ងៃ ទៅ ០៧ ថ្ងៃ ហើយត្រូវពិនិត្យលើសេចក្តីត្រូវការជាក់ស្តែងរបស់ភាគីនិយោជកផងដែរ។

តាមអង្គហេតុ និយោជកបញ្ជាក់ថា និយោជកអាចចេញតម្លៃឡូត៍ឱ្យកម្មករនិយោជិតដឹងបានក្នុងរយៈពេល៧ថ្ងៃ បន្ទាប់ពីកម្មករនិយោជិតធ្វើការងារលើឡូត៍នោះ ដោយបញ្ជាក់មូលហេតុថា ក្រុមហ៊ុនត្រូវការគិតគូពីតម្លៃទឹក ភ្លើង និងសន្តិសុខ ពិសេសគឺគិតពីបញ្ហាខាត ឬចំណេញសិន។ ចំណែកឯកម្មករនិយោជិតវិញទាមទារឱ្យក្រុមចេញតម្លៃឡូត៍ឱ្យកម្មករនិយោជិតដឹងបានក្នុងរយៈពេល៤ថ្ងៃ ដោយហេតុថា ទី១: ក្រុមហ៊ុនដទៃជិត១គ្នាប្រហាក់ប្រហែលគ្នា គេអាចធ្វើបាន។ ទី២: ផ្តល់លទ្ធភាពឱ្យក្រុមហ៊ុនរយៈពេល៣ថ្ងៃហើយ ឱ្យសាកល្បង និងសុំចេញតម្លៃឡូត៍នៅថ្ងៃទី០៤ ដោយក្រុមហ៊ុននេះទទួលផលិតផលពាក់កណ្តាលសម្រេច ដើម្បីធ្វើបន្តពីក្រុមហ៊ុនផ្សេង ហេតុនេះមានលទ្ធភាពច្រើនក្នុងការវាយតម្លៃជាមុនបាន ដោយការទទួលនេះមិនជាច្រើនពេកទេ។ ទី៣: កម្មករនិយោជិតទទួលបរិមាណផលិតផលពីក្រុមហ៊ុន ត្រូវតែឱ្យដឹងជាមុនអំពីតម្លៃឡូត៍ ដែលខ្លួនបានធ្វើជាក់ស្តែង ហើយក្រុមហ៊ុនត្រូវមានកាតព្វកិច្ចឱ្យកម្មករនិយោជិតបានដឹងជាមុន។ លើសពីនេះទៀត កម្មករនិយោជិតមិនព្រមទទួលយកការចេញតម្លៃឡូត៍ នៅថ្ងៃទី០៧ បន្ទាប់ពីកម្មករនិយោជិតធ្វើការងារលើឡូត៍នោះទេ ដោយសារតែការងារស៊ីឡូត៍ខ្លះ កម្មករនិយោជិតធ្វើហើយមុន៧ថ្ងៃ ដូចនេះការចេញតម្លៃឡូត៍នៅថ្ងៃទី៧ គឺក្រោយពេលកម្មករនិយោជិតធ្វើការលើឡូត៍នោះ ដែលជាហេតុធ្វើឱ្យកម្មករនិយោជិតមិនអាចដឹងតម្លៃឡូត៍មុនទេ។

យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកត្រូវចេញតម្លៃឡូត៍ឱ្យកម្មករនិយោជិតបានដឹងមុន តាមករណីការងារឡូត៍ជាក់ស្តែង ដែលមិនត្រូវចេញក្រោយកម្មករនិយោជិតធ្វើការលើឡូត៍នោះអស់ទេ ហើយរយៈពេលដែលចេញតម្លៃឡូត៍នោះត្រូវចេញក្នុងរយៈពេលពី០៣ថ្ងៃ ទៅ០៧ថ្ងៃ តាមករណីជាក់ស្តែង។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យនិយោជកចេញតម្លៃឡូត៍ឱ្យកម្មករនិយោជិតដឹងមុន ដោយមិនត្រូវចេញក្រោយកម្មករនិយោជិតធ្វើការលើឡូត៍នោះអស់ទេ ហើយរយៈពេលដែលចេញតម្លៃឡូត៍នោះត្រូវចេញក្នុងរយៈពេលពី០៣ថ្ងៃ ទៅ០៧ថ្ងៃ តាមករណីជាក់ស្តែង។

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី៥:** បង្គាប់ឱ្យនិយោជកចេញតម្លៃឡូត៍ឱ្យកម្មករនិយោជិតដឹងមុន ក្នុងរយៈពេលពី០៣ថ្ងៃ ទៅ០៧ថ្ងៃ តាមករណីជាក់ស្តែង ដែលមិនត្រូវចេញក្រោយកម្មករនិយោជិតធ្វើការលើឡូត៍នោះអស់ទេ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **កៅ ថាច**

ហត្ថលេខា: ----------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ម៉ែន ពៅ**

ហត្ថលេខា: ----------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **អ៊ឹង អេងថុង**

ហត្ថលេខា: ----------------------------